C:\New school\Private school2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ...៥៥៧........អយក.ប្រក

# ប្រកាស

## ស្តីពីការបើកសាលាចំណេះទូទៅឯកជន « វេស្ទើនអន្តរជាតិ »
## ស្ថិតនៅក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់លោក តែ ឡូរិន ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតអោយបើកសាលាចំណេះទូទៅឯកជន « វេស្ទើនអន្តរជាតិ » ពីថ្នាក់ទី ១ ដល់ទី ១២ ស្ថិតនៅក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២** : សាលារៀនឯកជន វេស្ទើនអន្តរជាតិ ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣** : លោក តែ ឡូរិន ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និង ផ្នែកបច្ចេកទេសព្រមទាំងទទួលខុសត្រូវក្នុងការ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សអោយចូលរៀន ។
- ធានាដំណើរបង្រៀន និងរៀនអោយបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាអោយមានសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញតាមកាលកំនត់ ។

**ប្រការ ៤** : ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងនាយកសាលារៀនសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២១ ខែ ១០ ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន"
- សាលាក្រុងភ្នំពេញ" ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ នា. មចទ